**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០១៤ ......សហវ.[illegible]

# សារាចរណែនាំ
## ស្តីពី
## ភាតព្វកិច្ចប្រកាសបង់ពន្ធលើប្រាក់បៀវត្សចំពោះកម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ ដែលទទួលបានប្រាក់បៀវត្សសរុបមុនពេលសម្រាកលំហែមាតុភាព

អនុលោមតាមប្រកាសលេខ ៥៧៥ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីពន្ធលើប្រាក់បៀវត្ស និងសេចក្តីណែនាំលេខ ០១៥/២៥ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីការការពារជាពិសេសចំពោះកម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពរបស់កម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ដូចខាងក្រោម៖

១. ចំពោះប្រាក់បៀវត្សរបស់កម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ ដែលត្រូវទទួលបានក្នុងអំឡុងពេលបំពេញការងារ, សហគ្រាសត្រូវកត់ត្រា និងប្រកាសបង់ពន្ធលើប្រាក់បៀវត្សនៅក្នុងខែដែលប្រាក់នោះបានបើក ដោយមិនគិតបញ្ចូលប្រាក់បៀវត្សអំឡុងពេលសម្រាកលំហែមាតុភាពដែលត្រូវបើកសរុបដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឡើយ។

២. ចំពោះប្រាក់បៀវត្សដែលត្រូវទទួលបានក្នុងអំឡុងពេលសម្រាកលំហែមាតុភាព ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលត្រូវបើកសរុបនៅក្នុងខែមុនពេលសម្រាកលំហែមាតុភាព សហគ្រាសមិនត្រូវកត់ត្រា និងប្រកាសបង់ពន្ធលើប្រាក់បៀវត្សសរុបរួមគ្នានៅក្នុងខែដែលបានបើកនោះទេ។ សហគ្រាសត្រូវកត់ត្រា និងប្រកាសបង់ពន្ធលើប្រាក់បៀវត្សជាប្រចាំខែដោយឡែកពីគ្នា ផ្អែកលើមូលដ្ឋានចំនួនប្រាក់បៀវត្សដែលត្រូវទទួលបានតាមខែនីមួយៗនោះ។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធ រោងចក្រ សហគ្រាស ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh